# ការសិក្សាឫសគល់ទស្សនវិជ្ជាខ្មែរ

*ដោយ៖* **បណ្ឌិត ប៉ាន់ ឌុត្ថា**
*អនុប្រធាននាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ការសិក្សាស្រាវជ្រាវអំពី ឫសគល់ទស្សនវិជ្ជាខ្មែរ ចាំបាច់យើងត្រូវមើលគំរូប្រព័ន្ធទស្សនវិជ្ជាក្នុងសាកលលោក ទាំងលោកខាងលិច ទាំងលោកខាងកើត ដើម្បីយកមកធ្វើជាប្រទីបក្នុងការឆ្លុះមើល និងជីករកឫសគល់ទស្សនវិជ្ជាខ្មែរ។*

## ១- ទស្សនវិជ្ជាបស្ចិមប្រទេស

*ទស្សនវិជ្ជាបស្ចិមប្រទេស មានប្រវត្តិមានប្រព័ន្ធមានគោលគំនិតសិក្សារួមហើយជាទូទៅមានទំនាស់នឹងគ្រិស្តសាសនាជាប្រចាំ។*

***ក- ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស*** *ចែកជា៦សម័យកាលគឺ បុរាណសម័យ មជ្ឈិមសម័យ បុនសម័យ សម័យពន្លឺ សម័យទំនើប និងសម័យក្រោយទំនើប។*

***ខ- មូលដ្ឋានគ្រឹះទស្សនវិជ្ជាបស្ចិមប្រទេសមាន*** *៖ ភាសាវិទ្យា អត្ថិរូបវិជ្ជា តក្កវិជ្ជា សោភ័ណវិជ្ជា សីលវិជ្ជា និង ទ្រឹស្តីពុទ្ធិ។*

***គ- ទ្រឹស្តីទស្សនវិជ្ជាបស្ចិមប្រទេស*** *អាចមានប្រភពចេញមកពីវិទូម្នាក់ៗ និងអាចមានប្រភពចេញមកពីទស្សនវិទូមួយក្រុម ដែលមានគំនិតស្របគ្នា មានវិធីសិក្សាដូចគ្នា មានកម្មវត្ថុសិក្សាដូចគ្នា មានទស្សន វិស័យ គោលបំណងគោលដៅ វត្ថុបំណង ដូចគ្នា ។*

*-ទស្សនៈរបស់ទស្សនវិទូម្នាក់ៗមានដូចជា៖ ទស្សនៈរបស់ សូក្រាត ប្លាតុង អារីស្តូត យេស៊ូ ដេកាត ហ្សង់ប៉ូលហ្សាត អាដាមស្មីត ហេហ្គែល កាលម៉ាក្ស លេនីន ជាដើម។*

*-ទស្សនៈរបស់ទស្សនវិទូមួយក្រុម ដែលមានគំនិតដូចគ្នា គេចាត់ចូលជា និកាយ មានដូចជា៖ និកាយអេលេ និកាយរូបធាតុនិយម និកាយមនោនិយម និកាយតថនិយម និកាយអត្ថិភាពនិយម និកាយទ្វិនិយម និកាយវិចារណញ្ញាណនិយម និ កាយបុគ្គលនិយម និកាយពិសោធន៍និយម និកាយផលប្រយោជន៍និយម ជាដើម។*

### *ឃ- អនុវត្តទ្រឹស្តីទស្សនវិជ្ជា*

*ទ្រឹស្តីទស្សនវិជ្ជាអាចយកទៅអនុវត្តក្នុងវិស័យផ្សេងៗនៅក្នុងសង្គម។*




## ២–ទស្សនវិជ្ជាបូព៌ាប្រទេស

*ទស្សនវិជ្ជាបូព៌ាប្រទេស គ្មានប្រព័ន្ធគ្មានគោលគំនិតសិក្សារួមទេ ទ្រឹស្តីទស្សនវិជ្ជាសិក្សាទៅតាមប្រទេសនីមួយៗរៀងៗខ្លួន ដូចជា៖ ទស្សនវិជ្ជាចិន ទស្សនវិជ្ជាឥណ្ឌា ទស្សនវិជ្ជាកូរ៉េ ទស្សនវិជ្ជាជប៉ុន ទស្សនវិជ្ជាវៀតណាម ទស្សនវិជ្ជាខ្មែរ ជាដើម ហើយជាទូទៅ ទស្សនវិជ្ជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងលាយចូលគ្នាជាមួយជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណី ។ ហេតុនេះ បើចង់សិក្សាទស្សនវិជ្ជាបូព៌ាប្រទេស គេត្រូវសិក្សាជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណី របស់ជនជាតិអាស៊ី មានន័យថា យល់ដឹងជំនឿ សាសនា និងទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិអាស៊ីគឺយល់ដឹងពីទស្សនវិជ្ជាបូព៌ាប្រទេស។*

## ៣- ឫសគល់ និងតម្លៃទស្សនវិជ្ជាខ្មែរ

*ទស្សនវិជ្ជា និង សាសនា កើតចេញពីឫសគល់តែមួយ ហើយរីកលូតលាស់រួមគ្នានៅក្នុងអរិយធម៌អាស៊ី។ ការសិក្សាពី ឫសគល់ទស្សនវិជ្ជាខ្មែរ ចាំបាច់ត្រូវរួមបញ្ចូលការសិក្សាឲ្យបានទូលំទូលាយ និងស៊ីជម្រៅនូវប្រព័ន្ធជំនឿខ្មែរដែលមានពីមុនៗមក ដូចជា ជំនឿតូតឹម ជំនឿវិញ្ញាណនិយម ជំនឿលើអ្នកតា ជំនឿលើប្រផ្នូល ជំនឿលើសម្បថ ជំនឿលើខ្មោច-ព្រាយ-បិសាច... ដំណាលគ្នានឹងការសិក្សា ព្រហ្មញ្ញសាសនា ពុទ្ធសាសនាទាំងមហាយាន ទាំងហិនយាន និងសាសនាផ្សេងៗទៀត ដែលមានវត្តមាននៅក្នុងសង្គមខ្មែរតាំងពីបុរាណរហូតមកដល់សព្វថ្ងៃនេះ។ ការសិក្សាពីសញ្ញាណឫសគល់ទស្សនវិជ្ជាខ្មែរ គឺផ្តោតទៅលើចំណុចសំខាន់ៗ៖*

### *ក–និកាយទស្សនវិជ្ជាខ្មែរ*

*និកាយ មានន័យថាជាសាលារៀន ជាកន្លែងកកើតគំនិតឬទស្សនៈក្នុងក្រុមមួយ។ របកគំហើញគំនិតឬទស្សនវិជ្ជាខ្មែរ អាចត្រូវបានរកឃើញចេញពី៣និកាយគឺ៖ **និកាយអាស្រម និកាយប្រាសាទ** និង **និកាយវត្ត** ដែលជា សាលាទិសាប៉ាម៉ោក។*

### *ខ– ទស្សនវិទូខ្មែរ*

*ក្នុងទស្សនៈរបស់ខ្មែរ ពាក្យទស្សនវិទូមានន័យស្មើនឹងអាចារ្យឬបណ្ឌិតាចារ្យៗ យោងតាមវចនានុក្រមខ្មែររបស់សម្តេច ជួន ណាត ថា៖*

អាចារ្យ ឬ អាចរិយៈ ឬ បណ្ឌិតាចារ្យ មានន័យថា អ្នកប្រដៅឬអ្នកបង្ហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នកដែលសិស្សត្រូវគោរព អ្នកធ្វើប្រយោជន៍ដល់សិស្ស អ្នកបង្រៀនចំណេះដឹងដល់គេ អ្នកអប់រំសីលធម៌ អ្នកផ្តល់ទស្សនាទាន។ សម័យមហានគរ (ស.វ.ទី៩ គ.ស.៨០២ ដល់ ស.វ.ទី១៤ គ.ស.១៣៣៦) គេឃើញមាន បណ្ឌិតាចារ្យ ជាច្រើនរូបសុទ្ធសឹងតែជាបណ្ឌិតធំៗ និងមានជំនាញច្បាស់លាស់ ដោយឡែកៗពីគ្នា ក្នុងនោះរួមមាន៖ បណ្ឌិត សិវសោម បណ្ឌិត យតិអមរភាវៈ បណ្ឌិត ទិវាករបណ្ឌិតកវិន្ទ្រៈបណ្ឌិតយោគីស្វរបណ្ឌិតកូបេន្ទ្រៈបណ្ឌិត ឥន្ទ្រទេវី បណ្ឌិត សិវាចារ្យ ...បណ្ឌិតាចារ្យទាំងអស់នេះ សុទ្ធតែជាអ្នកដឹកនាំពិធីសំខាន់ៗក្នុងព្រះរាជវាំង និងមានតួនាទីរៀបចំទំនៀមទម្លាប់របស់ព្រះមហាក្សត្រ និងមន្ត្រីជាន់ខ្ពស់ក្នុងសម័យនោះ។ ពិសេស បណ្ឌិតាចារ្យទាំងនោះ ដើរតួនាទីជាអាចារ្យបង្រៀនផង ជារាជគ្រូផង ជាស្ថាបត្យករផង ជាអ្នកចារសិលាចារឹក និងជាអ្នកផ្តល់ប្រឹក្សាដល់ព្រះមហាក្សត្រ ក្នុងការដឹកនាំប្រទេសជាតិផង។

**គ– ឫសគល់ទស្សនវិជ្ជាខ្មែរ**

**គ១–តូតឹមនិយម** (ទស្សនៈ និងជំនឿលើសត្វ ជំនឿលើដើមឈើ)

**–ទស្សនៈខ្មែរអំពីសត្វ**

ជំនឿតូតឹម គឺជាជំនឿលើសត្វដែលជាដើមសន្តតិវង្ស ជាអាទិទេពជាអវតាររបស់អាទិទេព ជាអ្នកនាំសាររវាងមនុស្សនិងអាទិទេព ជាភាវៈមានអំណាចស័ក្តសិទ្ធិដែលគួរឬត្រូវគោរពបូជា ជាភាវៈនាំមកនូវប្រផ្នូលល្អ ឬអាក្រក់។ សត្វទាំងនោះមានជាអាទិ៖ នាគ ក្រពើ អណ្តើក ត្រី គោ ក្របី តោ ខ្លា ដំរី គ្រុឌ ហង្ស លលកខ្មោច ខ្ទែងស្រោក ហ៊ីង គីង្គក់ៗល។ វត្តមានគំនូរ និងចម្លាក់សត្វ សរបញ្ជាក់ថា ខ្មែរបុរាណ ផ្សារភ្ជាប់ខ្លួនជាមួយបរិស្ថានដែលស្ថិតនៅជុំវិញខ្លួន ជានិមិត្តរូបនៃថាមពលធម្មជាតិដែលជាឫសកែវនៃជីវិត។ មនុស្ស បរិស្ថាន សត្វរុក្ខជាតិ មានអន្តរទំនាក់ទំនងគ្នា និងទ្រទ្រង់ស្ថេរភាពបរិស្ថាន។ ទន្ទឹមនឹងនេះដែរ រូបសត្វទាំងអស់នោះក៏អាចឆ្លុះបញ្ចាំងឱ្យយើងឃើញនូវជំនឿសាសនារបស់ជនជាតិខ្មែរនាសម័យបុរាណដែរ។ ក្នុងទស្សនៈខ្មែរយើងចាត់ទុក ត្រី នាគ ហ៊ីង គីង្គក់ ជាសត្វតំណាង ទឹក និងភ្លៀង។ ចាបឬបក្សី តំណាង ខ្យល់ឬអាកាស។ សត្វជើងបួនដូចជា គោ ក្របី តំណាង ដី។ សត្វ តំណាងនូវឥទ្ធិពលនៃធម្មជាតិដែលជាប្រភពនៃជីវិត និងទ្រទ្រង់ជីវិត។ ក្នុងជំនឿតូតឹមនេះទៀតសោត គឺគេជឿលើសត្វទាំងមូល ឬគ្រាន់តែជាភាគណាមួយនៅលើខ្លួនសត្វ ដូចជា ស្នែង ភ្លុក ចង្កូម ខ្នាយ ចែ ជាដើម។ ក្នុងពុទ្ធសាសនា ក៏បានផ្សារភ្ជាប់ប្រវត្តិព្រះពុទ្ធទាំង៥អង្គ មានរូប

*តំណាងព្រះពុទ្ធអង្គនីមួយៗក្រោមរូបភាពជាសត្វដែរ។*

***-ទស្សនៈខ្មែរអំពីដើមឈើ***

*ក្រៅពីជំនឿលើសត្វ ប្រជាជនខ្មែរក៏មានជំនឿលើដើមឈើផងដែរ។ គេជឿថា ដើមឈើធំៗសុទ្ធតែមានភូតអមនុស្សគ្រប់គ្រង កាន់កាប់ ឬជាជំរករបស់អារុក្ខ អារក្ខ អ្នកតា ខ្មោច ព្រាយបិសាច ដូចជា គេជឿថា ខ្មោចអាស្រ័យទីជម្រកនៅដើមចេកជ្វា ព្រាយបិសាចអាស្រ័យទីជម្រកនៅដើមអំពិល ឬដើមពោធិ។ ពេលគេសម្រាកស្នាក់អាស្រ័យក្រោមដើមឈើធំៗ ឬត្រូវបត់ជើងតូចធំក្បែរគល់ដើមឈើធំៗ និងកាប់ដើមឈើយកទៅធ្វើរបស់ប្រើប្រាស់ ឬធ្វើផ្ទះ គេត្រូវជម្រាបសុំអារុក្ខ អារក្ខ អ្នកតា ខ្មោច ព្រាយបិសាច មើលថែរក្សាដើមឈើនោះ បើមិនដូច្នោះទេ គេនឹងមិនមានសេចក្ដីសុខឡើយ។*

***គ៤-ទស្សនវិជ្ជាមនោនិយម***

*ទស្សនវិជ្ជាមនោនិយម ផ្ដោតការសិក្សាទៅលើ ជំនឿលើព្រលឹង ម្រេញគង្វាល ជំនាងផ្ទះ ព្រះភូមិ អ្នកតា ព្រលឹងមេបា(មាតាបិតេយ្យ) គ្រូអាចារ្យ គ្រូឧបជ្ឈាយ៍ គ្រូបាធ្យាយ កូនក្រក និងកូនព្រាយ អាបព្រាយបិសាច។ល។*

*ដោយការជឿលើព្រលឹងនេះហើយ ទើបប្រជាជនខ្មែរបានប្រារព្ធធ្វើពិធីជញ្ជាត់ព្រលឹង និងធ្វើទង់ព្រលឹងតំណាងព្រលឹងរបស់មនុស្សយើងនៅពេលស្លាប់ ព្រោះគេជឿថា រូបកាយយើងស្លាប់មែន តែព្រលឹងមិនស្លាប់ទេ។ គេមានជំនឿលើ កម្មពៀរ បុណ្យ បាប។ ខ្មែរមានជំនឿថា អ្នកដែលបានសាងអំពើបាបក្រោយពេលស្លាប់ទៅ ព្រលឹងរបស់គេនឹងត្រូវធ្លាក់ទៅក្នុងនរក។ នរកមាន៣២ជាន់។ ព្រលឹងនៅឋាននរកនោះ ក្លាយទៅជាប្រេត ហើយទទួលទារុណកម្មយ៉ាងសហាវព្រៃផ្សៃ ដូចជាដុតក្នុងភ្លើង ដាក់ចូលក្នុងខ្ទះខ្លាញ់ឬទឹកកំពុងពុះ ដុតដែកក្ដៅក្រហមរលៀលហើយយកមកចាក់ដោតលើស្បែក មិនបានទទួលសំណែនពីកូនចៅឧទ្ទិសឲ្យ ជាដើម។ ស្ត្រីដែលយកប្ដីគេដល់ពេលស្លាប់ធ្លាក់ទៅឋាននរក ត្រូវទទួលទារុណកម្មឡើងដើមរកាដែក។ នៅលើជញ្ជាំងប្រាសាទនានាតែងតែមានរូបចំលាក់ស្ដីពី រឿងបុណ្យបាប ពីនរក និងសួគ៌ និងរឿងជាច្រើនទៀត ដែលសុទ្ធសឹងជាមេរៀនសម្រាប់ពង្រឹងជំនឿ និងក្រមសីលធម៌។*

*រាល់ការដោះស្រាយបញ្ហាក្នុងជីវិតតថ: ពេលមនុស្សខ្មែរអសមត្ថភាព ខ្វះចំណេះដឹង ខ្វះបញ្ញា ខ្វះប្រាជ្ញា ខ្វះលទ្ធភាព គេបែរមកបន់ស្រន់ សែនព្រេន រកជំនួយពីកម្លាំងអធិធម្មជាតិ និងភូតអមនុស្ស ឲ្យមកជួយការពារ គាំពារ និងជួយដោះស្រាយបញ្ហាលំបាក ទុក្ខព្រួយជាដើម។ ការបន់ស្រន់គឺជាការលួងចិត្ត ជាការឃុំគ្រងស្មារតី ជាការលើកទឹកចិត្ត យើងចាត់ទុកវាជាទស្សនវិជ្ជាមួយដែលមនុស្សដាក់ចេញដើម្បីឲ្យ*

មានការតស៊ូតាំងចិត្តជំនះក្នុងការប្រតិបត្តិការងារក្នុងជីវិត។ នេះជា អាគមផ្សំអាយុ។

ក្រៅពីជំនឿលើព្រលឹង ប្រជាជនខ្មែរមានជំនឿលើ គ្រួណាម ប្រផ្នូលផ្សេងៗនិងការផ្សង ការស្បថ ការប្រើនិមិត្តរូបឧបកិច្ច និងការគោរពព្រះរស់ (ឪពុកម្ដាយ)ផងដែរ។

**គ៣–ទស្សនវិជ្ជារូបជាតុនិយម**

**(លោកជាតុវិទ្យា ៖ ទឹក ដី ភ្លើង ខ្យល់)**

បញ្ញត្តិ ទឹក ដី ភ្លើង ខ្យល់ នៅក្នុងទស្សនវិជ្ជាខ្មែរ មិនគ្រាន់តែមានអត្ថន័យត្រឹមតែជាលោកជាតុវិទ្យាដូចក្នុងទស្សនវិជ្ជាបស្ចិមប្រទេសទេ តែវាមានអត្ថន័យបន្ថែមជាច្រើនអនេកទាក់ទងនឹងជំនឿសាសនាផងដែរ ទាំងក្នុងជំនឿជីវចលនិយម ទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា។

**គ៤– ទស្សនវិជ្ជាទ្វិនិយម**

ទស្សនវិជ្ជាខ្មែរ កសាងឡើងលើគោលការណ៍ទ្វិនិយម។ ទស្សនៈទ្វិនិយម មានដូចជា ៖ អាក្រក់បៀមល្អ សបៀមខ្មៅ ក្ដៅបៀមត្រជាក់ ប្រុសនិងស្រី មេនិងបា នាមនិងរូប។ល។ ការផ្តុំភាពផ្ទុយគ្នា២ឲ្យទៅជាអង្គភាពរួមមួយ និមិត្តទៅជាកម្លាំង ជាថាមពល ជាសក្តានុពល។

**គ៥–ទស្សនវិជ្ជាលេខ**

លេខ តំណាងបរិមាណវត្ថុណាមួយ និងមានសារៈសំខាន់ក្នុងការគិតគូរជាអរូបិយ សម្រាប់បំរើផលប្រយោជន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ក្រៅពីតំណាងចំនួនមនុស្ស សត្វ ដើមឈើ វត្ថុអវិញ្ញាណកៈ លេខ ក៏បង្កប់នូវតម្លៃទស្សនវិជ្ជាយ៉ាងច្រើនក្នុងផ្នត់គំនិតប្រជាជនខ្មែរ ដោយផ្សារភ្ជាប់នឹងការងារ សកម្មភាពផ្សេងៗក្នុងជីវភាព តាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ ហើយនិងទាក់ទងនឹងជំនឿសាសនាផងដែរ។ ក្នុងផ្នត់គំនិតខ្មែរយល់ថា លេខគត់ លេខគូរ លេខសេស ទាក់ទងនឹងផ្កាយព្រះគ្រោះជាមួយនឹងជោគជតារាសីក្នុងទំនាក់ទំនងដំណើរជីវិត មាន ក្រ រាសីឡើង រាសីចុះ ការរស់នៅជួបជុំគ្នាមានសុភមង្គល ការព្រាត់ប្រាស វិនាសអន្តរាយ មានលាភ ជួបគ្រោះចង្រៃ ជាដើម។

**គ៦– ទស្សនវិជ្ជាលំហ**

លំហ ជារេខាគណិតមាត្រអរូប(គ្មានចម្ងាយ គ្មានទិស គ្មានទំហំ គ្មានរូបរាង និងគ្មានដែនឬមាត្រ)។ វត្តមាន លំហ (ទីកន្លែង) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាព និងមានសារៈសំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ផ្នត់គំនិតនយោបាយ សេដ្ឋកិច្ច (កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម) ការអប់រំ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿសាសនា ច្បាប់ សង្គមកិច្ច សុខាភិបាល រដ្ឋបាល ការចងក្រងប្រវត្តិសាស្ត្រ ការដាក់ស្ថាននាម ការរៀបចំនគរូបនីយកម្ម ដូចជា ការរៀបចំទីទួលភូមិឋាន ការសាងសង់សំណង់លំនៅដ្ឋាន ការសាងសង់សំណង់ប្រាសាទ ទីសក្ការៈ និងការ

ប្រារព្ធពិធីក្បួនវិតី ការរៀបចំកន្ទេងកប់សព ការរៀបចំទីកសិកម្ម ជីវដ្ឋាន ជលដ្ឋាន ប្រព័ន្ធគមនាគមន៍ ប្រព័ន្ធជាពសាស្ត្រ ការរៀបចំទីក្រុង ... សុទ្ធតែត្រូវបានបង្កើតចេញពីអានុភាពគំនិតទស្សនវិជ្ជា កាល-លំហ ទាំងអស់ ហើយវាក៏ឆ្លុះបញ្ចាំងពីអត្តចរិត អាកប្បកិរិយា របៀបរស់នៅ អន្តរទំនាក់ទំនងរវាងមនុស្សខ្មែរជាមួយ ទេវភូត អមនុស្ស ជោគជតាពាសីក្នុងការរស់នៅផងដែរ។

**គ៧– ទស្សនវិជ្ជាកាល**

វត្តមាន កាល (ពេលវេលា) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាព និងមានសារៈសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ពេលវេលា ដើរតួនាទីសំខាន់ក្នុងការកត់ត្រា ឬកំណត់កាលបរិច្ឆេទព្រឹត្តិការណ៍ និងមានបង្កប់នូវអត្ថន័យទស្សនវិជ្ជា យ៉ាងជ្រាលជ្រៅផងដែរ។ ក្នុងផ្នត់គំនិតខ្មែរ ថ្ងៃ ខែ ឆ្នាំ រដូវ ដើរតួនាទីយ៉ាងសំខាន់សម្រាប់គុណគូរនូវពល់ការទស្សន៍ទាយមើលពីពេលា ជោគជតាពាសី ការផ្សំផ្គុំគូរស្រករ ទស្សន៍ទាយមើលហេតុភេទដែលអាចនឹងកើតមានក្នុងការធ្វើដំណើរ និងក្នុងការប្រកបកិច្ចការអ្វីមួយ ការទស្សន៍ទាយពីជំងឺព្យាបាលបានឬមិនបាន និងការកំណត់ថ្ងៃអន្សារបស់មនុស្សម្នាក់ៗផងដែរ។ ក្នុងការរស់នៅប្រចាំថ្ងៃ ជតាពាសីជីវិតរបស់គេជួបរឿងល្អឬអាក្រក់ គឺអាស្រ័យទៅនឹងទីតាំងក្រុមផ្កាយទាំង៩ គិតធៀបមកលើផែនដី។ ខ្មែរមានជំនឿលើ ឆ្នាំ ខែ ថ្ងៃ អណ្តែត និង ឆ្នាំ ខែ ថ្ងៃលិច ដែលជាពេលាល្អណាស់ ឬ ពេលាល្អល្មម ឬ ពេលាអាក្រក់ ហើយគេជ្រើសរើសយកតែ ឆ្នាំ ខែ ថ្ងៃ ដែលជាពេលាមង្គល ជាពេលាល្អណាស់ ឬ ពេលាល្អល្មម សម្រាប់រៀបចំពិធីសំខាន់ៗ សម្រាប់ខ្លួនធ្វើអ្វីៗក្នុងជីវិត និងដើម្បីប្រារព្ធពិធីផ្សេងៗក្នុងសាសនា ដើម្បីឲ្យមានសិរីសួស្តី ជៀសវាងការខាតបង់ និងមានគ្រោះថ្នាក់។ រីឯ ឆ្នាំ ខែ ថ្ងៃ ដែលជា ពេលាអាក្រក់ គេមិនហ៊ានធ្វើពិធី និងសម្រេចធ្វើកិច្ចការអ្វីទេ ព្រោះគេបារម្ភណ៍ខ្លាចជួបគ្រោះថ្នាក់ឬខាតបង់ទ្រព្យសម្បត្តិ។ ដោយសារតែសារៈសំខាន់នៃពេលវេលានេះហើយ ដែលអាចធ្វើឲ្យខកខានក្នុងការប្រារព្ធពិធីក៏មាន ព្រោះតែរើសពេលាមិនបាន ឬពេលដែលត្រូវធ្វើនោះ កន្លងផុតទៅដោយគេមិនអាចរកថ្ងៃថ្មីមកជំនួស ដូចនេះ គេត្រូវរង់ចាំ ខែ ថ្ងៃ ដែលជាពេលាល្អនៅពេលក្រោយ។

**គ៨– ទស្សនវិជ្ជាជីវិត**

ក្នុងផ្នត់គំនិតខ្មែរមានច្បាប់និងកាតព្វកិច្ចដែលត្រូវបានផ្សារភ្ជាប់គ្នាក្នុងតំណាក់កាលផ្សេងៗនៃជីវិតរស់នៅរបស់គេ ដោយឆ្លងកាត់ពីភពមួយទៅភពមួយ ពីវ័យមួយទៅវ័យមួយ គេឲ្យឈ្មោះថា ពិធីឆ្លងភព ពីធីឆ្លងវ័យ ហើយពីធីនេះមានដូចជា៖ ពិធីកាត់សក់បង្កក់ឆ្មប អាពាហ៍ពិពាហ៍ ពិធីបុណ្យសព និងការកប់

ខ្មោចៗ ពិធីទាំងនេះឆ្លុះបញ្ចាំងពីគោលការណ៍សីលធម៌ក្នុងការរស់នៅរបស់ប្រជាជនខ្មែរ។




កិច្ចពិធីកាត់សក់បង្កក់ឆ្មប នៅខេត្តសៀមរាប

### គ៩- ទស្សនវិជ្ជាស្ត្រីនិយម (មាតាធិបតេយ្យ)

ទស្សនៈរបស់ខ្មែរ ផ្ទុយពីទស្សនៈរបស់ចិន និងទស្សនៈរបស់ឥណ្ឌា ដែលធ្លាប់បានជះឥទ្ធិពលរបស់ខ្លួនមកលើជាតិខ្មែរ។ ក្នុងសង្គមខ្មែរបានឱ្យតម្លៃខ្ពស់ទៅលើស្ត្រីថាៈ ស្ត្រីមានតួនាទីសំខាន់ណាស់ក្នុងការកំណត់ស្ថានភាព និងសុភមង្គលគ្រួសារ។ ចាស់បុរាណ លោកចាត់ទុកថា ទ្រព្យសម្បត្តិ កិត្តិយស ការស្រឡាញ់រាប់អានពីញាតិមិត្ត សិរីជ័យមង្គលនៅក្នុងគ្រួសារ គឺអាស្រ័យទៅលើសមត្ថភាព និងភាពប៉ិនប្រសប់របស់ស្ត្រីមេផ្ទះ។ ក្នុងគ្រួសារគេនិយមយកមេជាធំ គេរាប់ញាតិតាមខ្សែស្រឡាយខាងម្តាយ គឺសង្គមមាតាធិបតេយ្យ។ ក្នុងទស្សនៈនៃសង្គមមាតាធិបតេយ្យ ស្ត្រី គឺជានិមិត្តរូបនៃវប្បធម៌ ជាតិសាសន៍ សេរីសួស្តី សុភមង្គល កិត្តិយស សេចក្តីថ្លៃថ្នូរ សោភ័ណភាព ភាពសប្បាយរីករាយ ភាពទន់ភ្លន់ ក្នុងសង្គម។ មាតាធិបតេយ្យ គឺជាព្រលឹងរបស់ជនជាតិខ្មែរ ដែលឆ្លុះបញ្ចាំងពីទឹកចិត្ត និងផ្នត់គំនិតខ្មែរក្នុងវិស័យសេដ្ឋកិច្ច អប់រំ គ្រប់គ្រងគ្រួសារ ជំនឿ ទំនៀមទម្លាប់ ហើយមានអត្ថិភាពរហូតមកដល់សព្វថ្ងៃ ដូចជាពិធីឡើងផ្ទះថ្មី ពិធីចូលម្លប់ ពិធីសែនមេបា ពិធីពេលមានគត៌ ពិធីចែចូវ ពិធីស្តីដណ្តឹង ពិធីស៊ីស្លា ពិធីអាពាហ៍ពិពាហ៍ ជាដើម។

## សេចក្តីសន្និដ្ឋាន

អត្ថិភាពនៃជំនឿលើ រុក្ខជាតិ សត្វ ការគោរពទឹក ដី ភ្លើង ខ្យល់ ជំនឿលើលេខ ជឿលើព្រលឹងដូនតា អារុក្ខ អារក្ស ព្រលឹងមេបា ព្រាយបិសាច ការស្បថស្បែ ការប្រើនិមិត្តរូបឧបកិច្ច ... គឺជាគ្រឹះក្នុងទស្សនវិជ្ជាខ្មែរ។

ពីបុព្វកាលរៀងមក ត្បិតមែនតែមានឥទ្ធិពលគំនិតទស្សនវិជ្ជាពីបរទេសក៏ដោយ តែខ្មែរពុំនិយមយកមកអនុវត្តតាមឬចម្លងតាមទាំងដុលដែរ គឺខ្មែរតែងយកគំនិតទស្សនវិជ្ជាបរទេសទាំងនោះមកកែច្នៃផ្សែផ្សំឲ្យទៅជាលក្ខណៈជាតិ ស្របតាមទស្សនៈ និងផ្នត់គំនិតខ្មែរជាដរាប ពោលគឺ ខ្មែរបានធ្វើ ជាតូបនីយកម្ម ខ្មែរនីយកម្ម ខ្មែរភាវូបនីយកម្ម ដើម្បីតម្រូវទៅតាមទស្សនៈ ចំណង់ចំណូលចិត្ត ទំនៀមទម្លាប់ និងប្រពៃណីខ្មែរជានិច្ច។ រីឯលក្ខណៈបរទេស

*ណាដែលមិនស្រប មិនស៊ីគ្នានឹងទស្សនៈ ចំណង់ចំណូលចិត្ត ទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្មែរ ត្រូវខ្មែរផាត់ចោល ឬក៏ត្រូវសាបរលាបដោយខ្លួនឯងទៅវិញ។ ប៉ុន្តែ បច្ចុប្បន្ន ប្រជាជនខ្មែរខ្លះតែងចម្លងយកគំនិតទស្សនវិជ្ជាបរទេសមកអនុវត្តទាំងដុល និងឱ្យតម្លៃបរទេសខ្លាំងរហូតពេលខ្លះបំបាត់ទស្សនៈ ជំនឿ និងការគិតរបស់បុព្វបុរស និងការគិតរបស់ខ្លួនឯងចោល ដែលនេះជាបញ្ហាកង្វល់ក្នុងសង្គមខ្មែរសព្វថ្ងៃ។*

**ឯកសារពិគ្រោះ**


*១-ខ្លួត ធីតា៖ **ទស្សនវិជ្ជាខ្មែរសម័យអង្គរ** ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៨។*

*២-ត្រឹង ង៉ា៖ **អរិយធម៌ខ្មែរ** ភ្នំពេញ គ.ស. ១៩៧៤ បោះពុម្ពលើកទី៣។*

*៣-មីសែល ត្រាណេ៖ **ប្រព័ន្ធគំនិតខ្មែរ** ភាគ១។*

*៤-អ៊ុំ ប៉ុម៖ **គំនិតទស្សនវិជ្ជាខ្មែរតាមរយៈចំនួនលេខ** ភ្នំពេញ ២០០៩ ទំព័រ១-៦០។*

*៥-អាំង ជូលាន៖ **តួនាទីវត្តក្នុងការអប់រំនៅតំបន់អង្គរ** ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឆ្នាំ១៩៩៨។*

*៦-ង្វួន ញ៉ិល៖ **ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ** ភ្នំពេញ បោះពុម្ពនៅរោងពុម្ពកាសែតប្រជាជន១៩៩២។*